# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៩២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតពុទ្ធិកសាកលវិទ្យាល័យ
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៤អនក្រ/បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ/បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីលក្ខណៈវិនិច្ឆ័យនៃ ការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

# សម្រេច

**មាត្រា ១.-**

បង្កើតពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (Samdech Akka Moha Sena Padei Techo Hun Sen Buddhist University) ហៅកាត់ជាភាសាខ្មែរថា "ព.ស.ហ.ស និងជាភាសាអង់គ្លេស "H.S.B.U ដែលមានទីតាំងស្ថិតនៅវត្តសុទស្សនារាម ជ្រោយថ្ម សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម។ ពុទ្ធិកសាកលវិទ្យាល័យនេះស្ថិតនៅក្រោមឱវាទ របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និងសាសនា ។

**មាត្រា ២.-**

ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន មានតួនាទី និងភារកិច្ច អប់រំ បណ្តុះបណ្តាលសមណនិស្សិត និស្សិត សិក្សាស្រាវជ្រាវពុទ្ធសាសនា និងសាសនាឯទៀត រប្បធម៌ អក្សរសាស្ត្រ បាលី សំស្ក្រឹត និងវិទ្យាសាស្ត្រ។

**មាត្រា ៣.-**

ចំពោះមុខ ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ធ្វើការបណ្តុះបណ្តាលថ្នាក់ និងកម្រិតសិក្សា តាមបទដ្ឋានណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីសិក្សាត្រូវមានការឯកភាពពីក្រសួងធម្មការ និងសាសនា និងមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤.-**

ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដឹកនាំដោយសាកលវិទ្យាធិការ មួយរូបជាបព្វជិត ឬគ្រហស្ថ ដែលមានសមត្ថភាពសមស្រប និងសាកលវិទ្យាធិការរងមួយ ឬច្រើនរូប ជាជំនួយការដែលជាបព្វជិត ឬគ្រហស្ថ។

**មាត្រា ៥.-**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា ។

**មាត្រា ៦.-**

ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន មានពុទ្ធិកមហាវិទ្យាល័យ ចំនួន ០៥ ដូចខាងក្រោម ៖

១.ពុទ្ធិកមហាវិទ្យាល័យមនុស្សសាស្ត្រ និងភាសា

២.ពុទ្ធិកមហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ

៣.ពុទ្ធិកមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម

៤.ពុទ្ធិកមហាវិទ្យាល័យទស្សនវិទ្យា និងសាសនា

៥.ពុទ្ធិកមហាវិទ្យាល័យបាលី សំស្ក្រឹត

ទៅអនាគត ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អាច មាន ពុទ្ធិកមហាវិទ្យាល័យថ្មី បើកមុខជំនាញថ្មី សាខាថ្មី ឬពង្រីកកម្រិត ឬប្រភេទបណ្តុះបណ្តាល ដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

## មាត្រា ៧.-

សមណនិស្សិត និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយ ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អគ្គាធិការដ្ឋានពុទ្ធិកសិក្សាធិការជាតិ ហើយត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីពុទ្ធិកសាកលវិទ្យាល័យនេះ បានអនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការ នៃ ព.ស.ហ.ស ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១១

ស្ទីស្ការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
- គណៈសង្ឃនាយក
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ចាម
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ